# របាយការណ៍ប្រចាំខែមករា ឆ្នាំ ២០១៨ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ

នៅក្នុងខែមករា ឆ្នាំ២០១៨ មន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះបានបំពេញភារកិច្ចសម្រេចលទ្ធផលដូចខាងក្រោម÷

1. **<u>ស្ថានភាពមន្ត្រីរាជការ</u>**÷

ស្ថានភាពមន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ សរុបចំនួន៣០នាក់ ស្ត្រី០៤នាក់ និងដឹកនាំដោយប្រធានមន្ទីរ ០១រូប និងអនុប្រធានមន្ទីរ ០៣រូប។

2. **<u>សកម្មភាពថ្នាក់ដឹកនាំមន្ទីរ</u>** ÷

- ចូលរួមវេទិកាសាធារណៈ ចំនួន ០២ដង។
- ចូលរួមប្រជុំឆ្លងរបាយការណ៍ ស្តីពីសមិទ្ធផលសំខាន់ៗរបស់រដ្ឋបាលខេត្តក្រចេះ រយៈពេល៥ឆ្នាំ (២០១៣-២០១៧) ថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៨ នៅសាលប្រជុំសាលាខេត្ត។
- ចូលរួមក្នុងកម្មវិធីមីទិញអបអរសាទរខួបអនុស្សាវរីយ៍លើកទី៣៩ ទិវាជ័យជំនះ ៧មករា ថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៨ នៅមន្ទីរវប្បធមិ និងវិចិត្រសិល្បៈ។
- ចូលរួមក្នុងកម្មវិធីក្រុងពាលិបើកការដ្ឋានសាងសង់ស្តូបអនុស្សាវរីយ៍មិត្តភាពកម្ពុជា-វៀតណាម ថ្ងៃទី ១១ ខែមករា ឆ្នាំ២០១៨ នៅបរិវេណវិមានសព។
- ចូលរួមក្នុងកម្មវិធីសម្ពោធនូវសមិទ្ធផលនានាក្នុងវត្តសុគន្ធារាម (វត្តស្រែស្បូវ) ថ្ងៃទី១៧ ខែមករា ឆ្នាំ ២០១៨ នៅឃុំក្បាលដំរី។
- ចូលរួមក្នុងពីធីបើក និងបិទអង្គសន្និបាតបូកសរុបវាយតម្លៃការងារអប់រំ និងកីឡា ឆ្នាំសិក្សា២០១៦-២០១៧ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៨ នៅសាលប្រជុំមហោស្រពខេត្ត។
- ចូលរួមប្រជុំ គ.ក.ស.ក ប្រចាំខែមករា ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៨ នៅសាលប្រជុំក្រុមប្រឹក្សាខេត្ត។
- ចូលរួមប្រជុំសម្រេចលើសមិទ្ធផលក្រុមការងារចុះវាស់វែង និងផលប៉ះពាល់ផ្សេងៗស្ថិតនៅឃុំស្រែជិះ ឃុំរលួសមានជ័យ ស្រុកសំបូរ ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៨ នៅសាលប្រជុំសាលាខេត្ត។
- ចូលរួមប្រជុំសម្រេចលើសមិទ្ធផលក្រុមការងារចុះវាស់វែង និងផលប៉ះពាល់ផ្សេងៗស្ថិតនៅឃុំដំរីផុង ឃុំកំពង់ដំរី ស្រុកឆ្លូង ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៨ នៅសាលប្រជុំសាលាខេត្ត។
- ចូលរួមប្រជុំស្តីពីការរៀបចំ និងអនុវត្តសកម្មភាពអង្កេតរួមគ្នាពីស្ថានភាពទឹកស្អាត និងអនាម័យក្នុងសហគមន៍ ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៨ នៅសាលប្រជុំសាលាស្រុកសំបូរ។
- ចូលរួមប្រជុំ ជួបសំណេះសំណាលសម្តែងការគួរសម និងរាយការណ៍ជូនអំពីរបាយកាណ៍វឌ្ឍនភាពរបស់អង្គការសាម៉ារីតាន់ភឺស ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៨ នៅសាលប្រជុំសាលាខេត្ត។
- ចូលរួមក្នុងកម្មវិធីសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៧ និងទិសដៅឆ្នាំ២០១៨ របស់មន្ទីរដែនដី ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៨ នៅសាលប្រជុំសាកលវិទ្យាល័យក្រចេះ។

- ចូលរួមក្នុងកម្មវិធីប្រកាសតែងតាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទកម្ពុជា-កូរ៉េ ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៨ នៅខេត្តកំពង់ស្ពឺ។

3. **សកម្មភាពតាមការិយាល័យ÷**

3.1. **ការិយាល័យរដ្ឋបាល និងកិច្ចការទូទៅ**

**ក-ផ្នែកការងារលិខិតចូល÷ សរុបចំនួន ៤៣ លេខក្នុងនោះមានៈ**

- លិខិតចូលពីអង្គភាពនានាក្រោមនឹ្នរ ចំនួន ៣៥ លេខ
- លិខិតក្រសួងសាមី និងអង្គភាពក្រោមឱវាទមន្ទីរ ចំនួន ០៨ លេខ

**ខ-ផ្នែកការងារលិខិតចេញ ÷សរុបចំនួន ៤៤លេខ ក្នុងនោះមានៈ**

- លិខិតចេញទៅបណ្តាអង្គភាពនានាក្រោមនឹ្នរ ចំនួន ១៨ លេខ
- លិខិតចេញពាក់ព័ន្ធស្ថានភាពមន្ត្រីរាជការ ចំនួន ២៥ លេខ
- លិខិតចេញទូទៅ (លិខិតអញ្ជើញ និងជូនដំណឹង) ចំនួន ០០ លេខ
- លិខិតចេញទៅបណ្តាអង្គភាពនានា និងក្រសួងសាមី ចំនួន ០១ លេខ

**គ-ផ្នែកបញ្ជីវត្តមាន÷** ពិនិត្យការចុះបញ្ជីវត្តមានប្រចាំថ្ងៃ។

3.2. **ការិយាល័យផ្លូវលំជនបទ**

**សកម្មភាពការងារ**

- ចុះសិក្សាផ្លូវគម្រោងថែទាំជាលក្ខណៈសម្រាប់ផែនការឆ្នាំ ២០១៨ ចំនួន០១ ខ្សែ ប្រវែង ១៥ គម ស្ថិតនៅឃុំព្រែកប្រសព្វ និងឃុំសោប ស្រុកព្រែកប្រសព្វ។
- ចុះធ្វើបច្ចុប្បន្នផ្លូវប្រភេទទី៤ បានចំនួន ០៣ខ្សែ ប្រវែង ១៧.៧០ គម ស្ថិតនៅឃុំអូរគ្រៀង ស្រុកសំបូរ។

**លទ្ធផលការងារ**

- ចុះសិក្សាផ្លូវគម្រោងថែទាំជាលក្ខណៈសម្រាប់ផែនការឆ្នាំ ២០១៨ ចំនួន០១ ខ្សែ ប្រវែង ១៥ គម ស្ថិតនៅឃុំព្រែកប្រសព្វ និងឃុំសោប ស្រុកព្រែកប្រសព្វ។
- ចុះធ្វើបច្ចុប្បន្នផ្លូវប្រភេទទី៤ បានចំនួន០៣ខ្សែ ប្រវែង ១៧.៧០ គម ស្ថិតនៅឃុំអូរគ្រៀង ស្រុកសំបូរ។

3.3. **ការិយាល័យផ្គត់ផ្គង់ទឹកជនបទ**

- ចុះបង្កើតក្រុមការងារផែនការសុវត្ថិភាពទឹកឃុំដារ មានសមាសភាពចូលរួម ១៩នាក់ ស្ត្រី ០២រូប និងក្រុមការងារផែនការសុវត្ថិភាពទឹកថ្នាក់ភូមិ ចំនួន ០៩ភូមិ មានសមាសភាពសរុប ៤៥នាក់ ស្ត្រី ២៣នាក់ ក្រោមហិរញ្ញប្បទានអង្គការយូនីសេហ្វ។
- សហការណ៍ជាមួយ ChildFunds ស្តីពីវិធីសាស្ត្រថែទាំ ជួសជុលអណ្តូងស្នប់ សមាសសភាពសរុប ១៤នាក់ ស្ត្រី០៦រូប។

- សហការណ៍ជាមួយ ChildFunds ចុះស្រង់ទិន្នន័យអណ្តូងស្នប់ខូចបានចំនួន ៤៨អណ្តូង នៅស្រុកសំបូរ និងចិត្របុរី សម្រាប់ការជួសជុលឆ្នាំ២០១៨។

3.4. **<u>ការិយាល័យថែទាំសុខភាពជនបទ</u>**

- សកម្មភាពសិក្សាស្ថានភាពភូមិតាមរយៈ (PVA) ឃុំបុសលាវ ចំនួន ០៤ភូមិ សរុបអ្នកចូលរួមប្រជុំ សរុប ៤៦នាក់ ស្រ្តី ១៣នាក់÷ឃុំព្រែកសាម៉ាន់ ចំនួន ០៤ភូមិ សរុបអ្នក ចូលរួមប្រជុំ សរុប ៥៦នាក់ ស្រ្តី ១៧នាក់ ឃុំកោះតាសុយ ចំនួន ០៣ភូមិ សរុបអ្នក ចូលរួមប្រជុំ សរុប ៣៦នាក់ ស្រ្តី ០៨នាក់ ។
- ចូលរួមប្រជុំ ស្តីពីពិគ្រោះយោបល់លើការរៀបចំសកម្មភាពអង្កេតរួមគ្នាពីស្ថានភាពទឹកស្អាត និងការលើកកម្ពស់អនាម័យជនបទ នៅសាលាស្រុកសំបូរ ខេត្តក្រចេះ។
- បំផុសអោយប្រជាពលរដ្ឋចូលរួមស្មគ្រ័ចិត្តសាសង់បង្គន់ខ្លួនឯង÷ឃុំព្រែកសាម៉ាន់ ចំនួន ១៣ គ្រួសារ ឃុំសំបុកចំនួន ០៧ គ្រួសារ ឃុំកញ្ជរ ចំនួន២២ គ្រួសារ ឃុំកន្ទួតចំនួន ២១ គ្រួសារ ឃុំបុសលាវចំនួន ១២ គ្រួសារ ឃុំថ្មី ចំនួន ០៨ គ្រួសារ ឃុំខ្សាច់អណ្តែត ចំនួន ០៥ គ្រួសារ ឃុំដារ ចំនួន ២២ គ្រួសារ ឃុំគោលាប់ចំនួន ០៣គ្រួសារ ឃុំកោះច្រែងចំនួន០៥គ្រួសារ សង្កាត់ក្រគរចំនួន១០គ្រួសារ ឃុំកោះតាស៊ុយ ចំនួន ០២ គ្រួសារ។

3.5. **<u>ការិយាល័យអភិវឌ្ឍន៍សហគមន៍</u>**

- ចូលរួមសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងលើកទិសដៅការងារឆ្នាំ២០១៨ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅសាលមហោស្រពចតុមុខ ។
- បានចុះធ្វើបច្ចុប្បន្នភាព សមាសភាព គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ នៅតាមភូមិចំនួន ០៥ ភូមិ នៅក្នុងឃុំព្រែកសាម៉ាន់ ស្រុកឆ្លូង ខេត្តក្រចេះ ។
- បានចុះធ្វើបច្ចុប្បន្នភាព សមាសភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ នៅតាមភូមិចំនួន ០៤ ភូមិ នៅក្នុងឃុំកញ្ជរ ស្រុកឆ្លូង ខេត្តក្រចេះ ។

3.6. **<u>ការិយាល័យបណ្តុះបណ្តាល និងស្រាវជ្រាវ</u>**

លោក តូច សួង ប្រធានការិយាល័យអភិវឌ្ឍន៍ជនបទស្រុកចិត្របុរី និងលោកស្រី ស្រី ប៊ុន្នី មន្រ្តីការិយាល័យអភិវឌ្ឍន៍ជនបទក្រុងក្រចេះ បានចូលរួលសិក្ខាសាលាស្តីពី ដំណើរការ និងការថែទាំប្រពន្ធ័ប្រព្រឹត្តកម្មទឹកសម្អុយ លើកទី២ កាលពីថ្ងៃទៅ ០៩-១២ ខែមករា ឆ្នាំ ២០១៨ នៅសាលាស្រុកចិត្របុរី ខេត្តក្រចេះ ដែលរៀបចំដោយអង្គការ BORDA ។

4. **<u>ទិសដៅបន្ត</u>÷**

- ចុះស្រង់ទិន្នន័យផ្លូវ និងធ្វើបច្ចុប្បន្នភាពផ្លូវស្រុកសំបូរ និងស្រុកព្រែកប្រសព្វ។
- ចុះធ្វើបច្ចុប្បន្នភាព សមាសភាព គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) បន្តទៀត ។
- ចុះត្រួតពិនិត្យបច្ចេកទេសជួសជុលអណ្តូងស្នប់ខូច នៅស្រុកសំបូរ និងស្រុកចិត្របុរី។

- ចុះបំផុសសហគមន៍ទៅលើការប្រើប្រាស់ទឹក និងការបន្សុទ្ធទឹកតាមគ្រួសារនៅឃុំដារ។
- ចុះធ្វើបច្ចុប្បន្នភាពអណ្តូងនៅស្រុកស្នួល។
- បន្តការបំផុសអោយប្រជាពលរដ្ឋចូលរួមសាងសង់បង្គន់ដោយខ្លួនឯងក្នុងស្រុកឆ្លូង ស្រុកចិត្របុរី ស្រុកព្រែកប្រសព្វ ស្រុកសំបូរ និង ក្រុងក្រចេះ ។

**ប្រធានមន្ទីរ**